**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
លេខ : ១២៣ ដនស/ប្រ.ក/នី.ក

# ប្រកាស
# ស្តីពី
# បែបបទនៃការធានាត្រួតពិនិត្យនិងបញ្ជាក់ការធានាសាងសង់និងរុះរើ ផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យ



អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

លេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និង ទីប្រជុំជន

- បានឃើញអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្ដីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ២២៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះកំណត់អំពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់និងរុះរើ ផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់ ក្នុងគោលបំណងដើម្បីអនុវត្តអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់។

**ប្រការ២._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ៖

១- ការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់និងរុះរើផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់ អនុវត្តដោយក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២- ការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់និងរុះរើផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់ អនុវត្តដោយអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើផ្នែកមេកានិក អគ្គិសនី និងទឹក ត្រូវកំណត់ដោយប្រកាសដោយឡែក។

**ប្រការ៣._**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើ** សំដៅដល់ការត្រួតពិនិត្យ ការវិភាគ ការផ្ទៀងផ្ទាត់ និងការបញ្ជាក់លើប្រតិបត្តិការការងារសាងសង់ឬរុះរើអំពីភាពស្របតាមគម្រោងប្លង់ និងភាពអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដើម្បីជាមូលដ្ឋានសម្រាប់អាជ្ញាធរមានសមត្ថកិច្ចផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់សំណង់។

២- **ការងារសាងសង់** សំដៅដល់ការងារសាងសង់សំណង់ថ្មី ការងារជួសជុល និងការងារកែប្រែ។

៣- **ការងារសាងសង់សំណង់ថ្មី** សំដៅដល់ការងារសាងសង់ដែលចាប់ផ្តើមពីការងារដីឬការងារគ្រឹះ ការងារគ្រឿងផ្គុំ ការងារជញ្ជាំង ការងារដំឡើងរហូតដល់ការងារបង្ហើយដើម្បីបង្កើតសំណង់ថ្មីមួយ។

៤- **ការងារជួសជុល** សំដៅដល់ការជួសជុលផ្នែកណាមួយនៃសំណង់ឬការជួសជុលទាំងស្រុងដែលមានការខូចខាតដោយប្រការណាមួយ រួមទាំងការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ និងការកែលម្អ ការបំពាក់សម្ភារៈបរិក្ខារផ្នែកផ្សេងទៀតនៅខាងក្នុងដោយរក្សាសោភណភាព ទ្រង់ទ្រាយដើម និងមិនប៉ះពាល់ដល់គ្រឿងផ្គុំសំណង់។

៥- **ការងារកែប្រែ** សំដៅដល់ការផ្លាស់ប្តូរមុខងារទ្រង់ទ្រាយទាំងស្រុងឬផ្នែកណាមួយនៃសំណង់។

៦- **ការងាររុះរើ** សំដៅដល់ការរុះរើដោយផ្នែកដែលជាការងារដោះឬដកចេញនូវចំណែកណាមួយនៃសំណង់ ឬការងាររុះរើទាំងស្រុងដែលជាការដកចេញសំណង់ទាំងមូល ឬការងារវាយកម្ទេចសំណង់ទាំងមូលទាំងនៅលើដី ទាំងនៅក្រោមដី លើកលែងតែគ្រឹះនៃសំណង់ដែលអាចរក្សាទុក។

៧- **គម្រោងប្លង់** សំដៅដល់ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ និងសេចក្តីណែនាំបច្ចេកទេសពាក់ព័ន្ធ សម្រាប់ការងារសាងសង់ឬរុះរើ ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច សម្រាប់បម្រើដល់ការងារសំណង់។

៨- **គម្រោងអភិវឌ្ឍអចលនវត្ថុ** សំដៅដល់គម្រោងអភិវឌ្ឍបុរី គម្រោងអភិវឌ្ឍអគារសហកម្មសិទ្ធិ ឬគម្រោងសាងសង់ផ្សេងទៀតក្នុងគោលដៅក្រៅពីលំនៅឋានផ្ទាល់ខ្លួន ដែលមានលិខិតអនុញ្ញាតសាងសង់តែមួយ។

៩- **ត្រាវិជ្ជាជីវៈ** សំដៅដល់ត្រាចេញដោយគណៈវិជ្ជាជីវៈពាក់ព័ន្ធជូនដល់អ្នកវិជ្ជាជីវៈសម្រាប់ប្រើប្រាស់ក្នុងការប្រកបវិជ្ជាជីវៈ។

១០- **លិខិតបញ្ជាក់អនុលោមភាព** សំដៅដល់លិខិតចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដើម្បីបញ្ជាក់ថាការងារសាងសង់ឬរុះរើ ស្របតាមគម្រោងប្លង់ និងអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត។

១១- **របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាព** សំដៅដល់របាយការណ៍បច្ចេកទេសទាក់ទងនឹងការត្រួតពិនិត្យ ការវាយតម្លៃគុណភាពការងារសាងសង់ឬសំណង់ស្របតាមលក្ខខណ្ឌនៃបទប្បញ្ញត្តិបច្ចេកទេសសំណង់ បទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀតដែលរៀបចំដោយអ្នកសាងសង់ឬទីប្រឹក្សាគម្រោង។

១២- **អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់** សំដៅដល់ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់។

១៣- **អ្នកសាងសង់** សំដៅដល់អ្នកទទួលម៉ៅការសាងសង់ឬសំណង់ អ្នកសាងសង់ឬសំណង់តាមជំនាញឬក្រុមជាងសំណង់។

១៤- **អាជ្ញាបណ្ណ** សំដៅដល់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

១៥- **ឯកសារទម្រង់អេឡិចត្រូនិក** សំដៅដល់ឯកសារដែលផ្ទុកនូវព័ត៌មាន ឬទិន្នន័យដែលអាចយកមកដំណើរការដោយកុំព្យូទ័រ ធ្វើការកែប្រែ និងចែករំលែករវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

១៦- **ឯកសារទម្រង់ឌីជីថល** សំដៅដល់ ទី១)ឯកសារដែលមានទម្រង់ជា Portable Document Format(PDF) ឬរូបភាព(JPEG,PNG,...) សម្រាប់ប្រើប្រាស់ជាឯកសារយោងឬភ្ជាប់ដែលបានស្កេនឬថតចេញពីឯកសាររូបី ឬ ទី២)ឯកសារដែលមានទម្រង់ជា PDF ឬរូបភាពដែលប្រើប្រាស់សម្រាប់បោះពុម្ពប្រើប្រាស់ជាផ្លូវការបាន។

១៧- **ឯកសារបច្ចេកទេស** សំដៅដល់គម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក សេចក្តីណែនាំបច្ចេកទេស ប្លង់សម្រង់សំណង់ ប្លង់សម្រង់តាមការសាងសង់ជាក់ស្តែង វិញ្ញាបនបត្រប្រើប្រាស់សំណង់ ឯកសារសិក្សាភូគព្ភសាស្ត្រ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ឯកសារសិក្សាសមិទ្ធលទ្ធកម្ម សៀវភៅបន្ទុកនៃការងារសាងសង់ របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់សំណង់ លិខិតបញ្ជាក់អនុលោមភាព របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ របាយការណ៍ស្តីពីការពិសោធន៍ របាយការណ៍ស្តីពីការគណនា និងរបាយការណ៍ស្តីពីការធ្វើកោសល្យវិច័យសំណង់ គម្រោងប្លង់ឬរបាយការណ៍បច្ចេកទេសដទៃទៀត។

១៨- **ឯកសាររឹង** សំដៅដល់ឯកសារដែលមានទម្រង់ជាក្រដាស។

## ជំពូកទី២

## វិធានរួមនៃការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់និងរុះរើ

**ប្រការ៤._**

ចំណាត់ថ្នាក់ ប្រភេទ និងទំហំនៃសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើ ត្រូវបានកំណត់ដូចតទៅ៖

១- សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២- សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

**ប្រការ៥._**

ការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ឬការងាររុះរើ អាចធ្វើឡើងតាមការស្ម័គ្រចិត្តចំពោះសំណង់ដូចតទៅ៖

១- សំណង់សាសនាសម្រាប់ដាក់ឱ្យប្រើប្រាស់ដោយសាធារណជនដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

២- សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

ចំពោះសំណង់សាសនាសម្រាប់ដាក់ឱ្យប្រើប្រាស់ដោយសាធារណជនដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ពុំមានការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ឬការងាររុះរើដោយក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ទេ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវទទួលបន្ទុកត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៃការងារសាងសង់ឬរុះរើនោះ។

ចំពោះសំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពុំមានការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ឬការងាររុះរើ ដោយអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ទេ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៃការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ឬការងាររុះរើនោះ។

**ប្រការ៦._**

ការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ និងការងាររុះរើ ត្រូវអនុវត្តតាមបែបបទដូចមានចែងក្នុងប្រកាសនេះ។

ម្ចាស់សំណង់ត្រូវចុះកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ជាមួយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលមានអាជ្ញាបណ្ណនៅមានសុពលភាព ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ឬការងាររុះរើរបស់ខ្លួន មុននឹងស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់។

រាល់ការចំណាយសម្រាប់ការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់និងរុះរើជាបន្ទុករបស់ម្ចាស់សំណង់។

**ប្រការ៧._**

ការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់និងរុះរើ ត្រូវអនុវត្តនៅពេលដំណើរការការងារសាងសង់ឬរុះរើនៅការដ្ឋានសំណង់ផ្ទាល់ ដោយផ្ទៀងផ្ទាត់ការងារសាងសង់ឬរុះរើជាមួយគម្រោងប្លង់ និងដោយផ្អែកលើបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតដើម្បីធ្វើការវាយតម្លៃនិងសន្និដ្ឋាន។

**ប្រការ៨._**

ម្ចាស់សំណង់ត្រូវប្រគល់ជូនអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ នូវគម្រោងប្លង់និងឯកសារបច្ចេកទេសពាក់ព័ន្ធនឹងការងារសាងសង់ឬរុះរើ ទាំងជាឯកសាររឹង ទាំងជាឯកសារទម្រង់ឌីជីថល ទាំងជាឯកសារទម្រង់អេឡិចត្រូនិក។

ក្នុងករណីម្ចាស់សំណង់ប្រគល់ប្លង់ សេចក្តីណែនាំបច្ចេកទេស និងរបាយការណ៍ស្តីពីការគណនាជាឯកសារទម្រង់ឌីជីថលនិងឯកសារទម្រង់អេឡិចត្រូនិក ជូនអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ម្ចាស់សំណង់ត្រូវអនុវត្តដូចតទៅៈ

- ត្រូវការពារប្រឆាំងនឹងការផ្លាស់ប្តូរទិន្នន័យនៃប្លង់ សេចក្តីណែនាំបច្ចេកទេស និងរបាយការណ៍ស្តីពីការគណនានោះ
- ត្រូវប្រគល់ប្លង់ សេចក្តីណែនាំបច្ចេកទេស និងរបាយការណ៍ស្តីពីការគណនាជាឯកសារទម្រង់ឌីជីថល និងឯកសារទម្រង់អេឡិចត្រូនិក ដំណាលគ្នាជាមួយនឹងការប្រគល់គម្រោងប្លង់ជាឯកសាររឹង។

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់មានសិទ្ធិចម្លងទិន្នន័យនៅក្នុងឯកសារទម្រង់ឌីជីថលនិងឯកសារទម្រង់អេឡិចត្រូនិកដើម្បីប្រើប្រាស់សម្រាប់តែការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើប៉ុណ្ណោះ។

ក្នុងករណីបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតតម្រូវ ម្ចាស់សំណង់ត្រូវប្រគល់ឯកសារបច្ចេកទេសផ្សេងទៀតពាក់ព័ន្ធនឹងការងារសាងសង់ឬរុះរើជូនអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ទាំងជាឯកសាររឹង ទាំងជាឯកសារទម្រង់ឌីជីថល ទាំងជាឯកសារទម្រង់អេឡិចត្រូនិក។

ក្រោយពីទទួលបានឯកសារបច្ចេកទេសពីម្ចាស់សំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវចេញលិខិតប្រគល់ទទួលឯកសារដែលមានកាលបរិច្ឆេទនិងហត្ថលេខារបស់ភាគីទាំងពីរ។

គំរូទម្រង់លិខិតប្រគល់ទទួលឯកសារបច្ចេកទេស ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ។

**ប្រការ៩._**

អ្នកសាងសង់ត្រូវផ្តល់កាលវិភាគការងារសាងសង់ឬរុះរើនិងជូនដំណឹងអំពីការផ្លាស់ប្តូរកាលវិភាគនោះដល់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវរៀបចំកាលវិភាគការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើរបស់ខ្លួនផ្អែកលើកាលវិភាគការងារសាងសង់ឬរុះរើនោះ។ ក្នុងករណីមានការផ្លាស់ប្តូរកាលវិភាគការងារសាងសង់ឬរុះរើ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវកែសម្រួលកាលវិភាគការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើឡើងវិញ។

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវរៀបចំបញ្ជីត្រួតពិនិត្យការងារជូនអ្នកសាងសង់ដើម្បីធ្វើការត្រួតពិនិត្យនៅមុនពេល ក្នុងពេល និងក្រោយពេលអនុវត្តការងារសាងសង់ឬរុះរើ។

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវផ្តល់មូលវិចារលើរាល់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពដែលរៀបចំដោយអ្នកសាងសង់។

ក្នុងករណីពិនិត្យឃើញថាការងារសាងសង់ឬរុះរើមិនស្របតាមគម្រោងប្លង់ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬបទប្បញ្ញត្តិជាធរមានណាមួយ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកសាងសង់និងម្ចាស់សំណង់។ ក្នុងករណីនេះ អ្នកសាងសង់ត្រូវធ្វើការកែតម្រូវជាបន្ទាន់។

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចនិងម្ចាស់សំណង់ជាបន្ទាន់ ក្នុងករណីអ្នកសាងសង់នៅតែបន្តអនុវត្តការងារផ្ទុយពីការណែនាំរបស់ខ្លួន។

គំរូទម្រង់លិខិតជូនដំណឹង ជាឧបសម្ព័ន្ធ២នៃប្រកាសនេះ។

**ប្រការ១០.**_

លិខិតបញ្ជាក់អនុលោមភាពនៃការងារសាងសង់ឬរុះរើ អាចចេញបានតែក្នុងករណីការងារសាងសង់ឬរុះរើស្របតាមគម្រោងប្លង់ និងអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត។

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចចេញលិខិតបញ្ជាក់អនុលោមភាពនៃការងារសាងសង់ឬរុះរើមួយបានតែម្តងគត់លើកលែងតែមានការតម្រូវដោយអាជ្ញាធរមានសមត្ថកិច្ច។

លិខិតបញ្ជាក់អនុលោមភាពមួយ អាចចេញបានសម្រាប់តែគម្រោងសាងសង់ឬរុះរើតែមួយប៉ុណ្ណោះ។

**ប្រការ១១.**_

ក្នុងករណីការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើក្នុងគម្រោងតែមួយ ត្រូវបានអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់តែមួយដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់នោះអាចចេញលិខិតបញ្ជាក់អនុលោមភាពតែមួយទាំងផ្នែកគ្រឿងផ្គុំសំណង់ ទាំងផ្នែកស្ថាបត្យកម្មបាន។

ក្នុងករណីការងារសាងសង់ឬរុះរើក្នុងគម្រោងតែមួយត្រូវបានត្រួតពិនិត្យនិងបញ្ជាក់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់តែមួយ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់នោះ ត្រូវចេញរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើនៅតាមដំណាក់កាលនៃការងារ និងធ្វើការបញ្ជាក់អនុលោមភាពនៃការងារសាងសង់ឬរុះរើនៅក្រោយការងារសាងសង់ឬរុះរើត្រូវបានបញ្ចប់។

ក្នុងករណីការងារសាងសង់ឬរុះរើក្នុងគម្រោងតែមួយត្រូវបានត្រួតពិនិត្យនិងបញ្ជាក់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្សេងៗគ្នា អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់នីមួយៗ ត្រូវចេញរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើតាមដំណាក់កាលរៀងៗខ្លួននិងធ្វើការបញ្ជាក់អនុលោមភាពនៃការងារសាងសង់ឬរុះរើតាមដំណាក់កាលនៅលើលិខិតបញ្ជាក់អនុលោមភាពតែមួយទៅតាមការងារដូចមានចែងក្នុងកិច្ចសន្យារៀងៗខ្លួន។

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវប្រគល់ជូនម្ចាស់សំណង់នូវច្បាប់ដើមនៃរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើតាមដំណាក់កាល។

ច្បាប់ដើមនៃលិខិតបញ្ជាក់អនុលោមភាពនៃការងារសាងសង់ឬរុះរើ ត្រូវតម្កល់ទុកនៅម្ចាស់សំណង់។

គំរូទម្រង់របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់នៅតាមដំណាក់កាល ជាឧបសម្ព័ន្ធ៣នៃប្រកាសនេះ។

គំរូទម្រង់របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើផ្នែកស្ថាបត្យកម្ម នៅតាមដំណាក់កាល ជាឧបសម្ព័ន្ធ៤នៃប្រកាសនេះ។

គំរូទម្រង់លិខិតបញ្ជាក់អនុលោមភាពនៃការងារសាងសង់ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់តាមដំណាក់កាលរបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ច្រើន ជាឧបសម្ព័ន្ធ៥នៃប្រកាសនេះ។

គំរូទម្រង់លិខិតបញ្ជាក់អនុលោមភាពនៃការងារសាងសង់ឬរុះរើផ្នែកស្ថាបត្យកម្មតាមដំណាក់កាលរបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ច្រើន ជាឧបសម្ព័ន្ធ៦នៃប្រកាសនេះ។

គំរូទម្រង់លិខិតបញ្ជាក់អនុលោមភាពនៃការងារសាងសង់ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់ឬផ្នែកស្ថាបត្យកម្មរបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់តែមួយ ជាឧបសម្ព័ន្ធ៧នៃប្រកាសនេះ។

គំរូទម្រង់លិខិតបញ្ជាក់អនុលោមភាពនៃការងារសាងសង់ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់និងផ្នែកស្ថាបត្យកម្មរបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់កាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅ ជាឧបសម្ព័ន្ធ៨នៃប្រកាសនេះ។

**ប្រការ១២._**

ក្នុងករណីអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវបានប្តូរ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ថ្មី ត្រូវប្រើរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើ លិខិតបញ្ជាក់អនុលោមភាពនៃការងារសាងសង់ឬរុះរើ និង/ឬរបាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពដែលមានមូលវិចាររបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់មុន ដើម្បីអនុវត្តការងារបន្ត។

ក្នុងករណីអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ឈប់ឬត្រូវបានបញ្ឈប់ពីការងារនៃគម្រោងសាងសង់ឬរុះរើណាមួយ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់នោះ ត្រូវចេញរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើនិងលិខិតបញ្ជាក់អនុលោមភាពលើត្រឹមការងារសាងសង់ឬរុះរើដែលខ្លួនបានត្រួតពិនិត្យក្នុងរយៈពេលយ៉ាងយូរ១៤ថ្ងៃគិតចាប់ពីថ្ងៃដែលម្ចាស់សំណង់ទទួលបានសេចក្តីជូនដំណឹងអំពីការឈប់ឬគិតចាប់ពីថ្ងៃដែលអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ទទួលបានសេចក្តីជូនដំណឹងអំពីការបញ្ឈប់នោះ។

ក្នុងករណីអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់មិនបានចេញរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើនិងលិខិតបញ្ជាក់អនុលោមភាពក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ១៣._**

របាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើ ត្រូវមានហត្ថលេខា គោត្តនាម និងនាម ត្រាវិជ្ជាជីវៈ និងលេខអាជ្ញាបណ្ណរបស់អ្នកវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬហត្ថលេខា និងគោត្តនាមនិងនាមរបស់អ្នកបច្ចេកទេសនិងនាយកបច្ចេកទេស ត្រា និងលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ឬហត្ថលេខារបស់ប្រធានក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់និងត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លិខិតបញ្ជាក់អនុលោមភាពនៃការងារសាងសង់ឬរុះរើ ត្រូវមានហត្ថលេខា គោត្តនាមនិងនាម ត្រាវិជ្ជាជីវៈ និងលេខអាជ្ញាបណ្ណរបស់អ្នកវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬហត្ថលេខានិងគោត្តនាម និងនាមរបស់នាយកបច្ចេកទេស ត្រា និងលេខអាជ្ញាបណ្ណរបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ឬហត្ថលេខារបស់ប្រធានក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់និងត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ១៤._**

ម្ចាស់សំណង់ត្រូវប្រគល់ជូនអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ នូវប្លង់សម្រង់តាមការសាងសង់ជាក់ស្តែងដែលបានចុះហត្ថលេខាដោយអ្នកសាងសង់តាមប្រភេទការងារសាងសង់ឬការងាររុះរើដោយផ្នែកដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនិងបញ្ជាក់នោះ។

ក្នុងករណីម្ចាស់សំណង់ចុះកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ជាមួយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ច្រើនដើម្បីធ្វើការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើ ម្ចាស់សំណង់ត្រូវប្រគល់ប្លង់សម្រង់តាមការសាងសង់ជាក់ស្តែងដែលបានចុះហត្ថលេខាដោយអ្នកសាងសង់ ជូនអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់នីមួយៗ។

ក្រោយពីទទួលបានប្លង់សម្រង់តាមការសាងសង់ជាក់ស្តែងពីម្ចាស់សំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវចេញលិខិតប្រគល់ទទួលប្លង់សម្រង់តាមការសាងសង់ជាក់ស្តែងដែលមានកាលបរិច្ឆេទនិងហត្ថលេខានៃភាគីទាំងពីរ។

គំរូទម្រង់លិខិតប្រគល់ទទួលប្លង់សម្រង់តាមការសាងសង់ជាក់ស្តែង ជាឧបសម្ព័ន្ធ៩នៃប្រកាសនេះ។

**ប្រការ១៥._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវត្រួតពិនិត្យភាពត្រឹមត្រូវនៃប្លង់សម្រង់តាមការសាងសង់ជាក់ស្តែងដែលគូរដោយអ្នកសាងសង់។

ក្នុងករណីពិនិត្យឃើញថាប្លង់សម្រង់តាមការសាងសង់ជាក់ស្តែងមានភាពត្រឹមត្រូវ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវចុះហត្ថលេខា គោត្តនាមនិងនាម និងត្រាវិជ្ជាជីវៈរបស់អ្នកវិជ្ជាជីវៈត្រួតពិនិត្យនិង

បញ្ជាក់សំណង់ ឬហត្ថលេខានិងគោត្តនាមនិងនាមរបស់នាយកបច្ចេកទេស និងត្រារបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ ឬហត្ថលេខារបស់ប្រធានក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់និងត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងកាលបរិច្ឆេទនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់ នៅលើគ្រប់សន្លឹកនៃប្លង់សម្រង់តាមការសាងសង់ជាក់ស្តែង។

ក្នុងករណីប្លង់សម្រង់តាមការសាងសង់ជាក់ស្តែង មិនត្រឹមត្រូវឬខុសពីសំណង់ដែលបានសាងសង់រួចឬសំណង់ដែលនៅសល់ពីការរុះរើ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវជូនដំណឹងទៅអ្នកសាងសង់ឱ្យកែតម្រូវ។

**ប្រការ១៦._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវប្រគល់ប្លង់សម្រង់តាមការសាងសង់ជាក់ស្តែងជាឯកសារទម្រង់ Portable Document Format(PDF) និងឯកសាររឹងជូនម្ចាស់សំណង់សម្រាប់បំពេញបែបបទស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់។

## ជំពូកទី៣
## ការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់សំណង់ថ្មី

**ប្រការ១៧._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់សំណង់ថ្មី មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យការងារសាងសង់ឱ្យស្របតាមគម្រោងប្លង់ស្ថាបត្យកម្មនិងគម្រោងប្លង់គ្រឿងផ្គុំសំណង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចនិងមន្ត្រីមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត
- ត្រួតពិនិត្យការងារសាងសង់ឱ្យអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ស្តង់ដាកម្ពុជា និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ត្រួតពិនិត្យការដ្ឋានសំណង់ឱ្យដំណើរការដោយគោរពតាមលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំពាក់ព័ន្ធ មានជាអាទិ៍ សុវត្ថិភាព បរិស្ថាន អនាម័យ សន្តិសុខ សណ្តាប់ធ្នាប់នៅការដ្ឋានសំណង់
- បញ្ជាក់ថាសំណង់ដែលបានសាងសង់មានគុណភាពនិងសុវត្ថិភាពក្នុងការប្រើប្រាស់។

**ប្រការ១៨._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់សំណង់ថ្មី ត្រូវអនុវត្តលើការងារដូចខាងក្រោម៖

១- ការងារសាងសង់ផ្នែកនគរូបនីយកម្ម មានជាអាទិ៍ ប្លង់ម្ចាស់ កម្ពស់សំណង់ សន្ទស្សន៍ប្រើប្រាស់ដី ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ការប្រើប្រាស់លំហសាធារណៈ និងផ្ទៃបៃតង ចំណតយានយន្តក្រៅអគារ។

២- ការងារសាងសង់គ្រឿងផ្គុំផ្នែកខាងក្រោម មានជាអាទិ៍ ការងារគ្រឹះ ការងារគម្របសសរគ្រឹះ ការងារជញ្ជាំងទប់ដី ការងារទប់ជញ្ជាំង ការងារធ្នឹមក្រវ៉ាត់ ការងារសសរតឿ គ្រឿងផ្គុំផ្នែកខាងលើ មានជាអាទិ៍ ការងារធ្នឹម ការងារសសរ ការងារកម្រាលខណ្ឌ ការងារជញ្ជាំងទ្របន្ទុក ការងារជណ្ដើរ ការងារដំបូល និងការងារពុម្ព មានជាអាទិ៍ ការងាររៀបពុម្ព ការងាររន្ទា ការងារជន្ទល ការងារដែកពង្រឹង។

៣- ការងារសាងសង់ផ្នែកស្ថាបត្យកម្ម មានជាអាទិ៍ ដំបូល ទ្វារ បង្អួច ជណ្ដើរ កម្ពស់ ច្រកចេញចូល លំហខ្យល់ចេញចូល ពន្លឺ ចំណតយានយន្តក្នុងអគារ ហេដ្ឋារចនាសម្ព័ន្ធរួបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព មុខងារសមាសភាគសំណង់ ភ្លើងសញ្ញាអាកាសចរលើដំបូលអគារ និងឧបករណ៍ការពាររន្ទះ។

៤- ការងារសាងសង់ផ្នែកប្រព័ន្ធទឹកកខ្វក់និងប្រព័ន្ធទឹកភ្លៀង មានជាអាទិ៍ បណ្ដាញលូបង្ហូរទឹកកខ្វក់ បណ្ដាញលូបង្ហូរទឹកភ្លៀង អាងសិបទិច អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ទទឹកភ្លៀង អាងស្ដុកទឹកភ្លៀង អាងប្រព្រឹត្តិកម្មសម្អាតសំណល់រាវ។

៥- ការងារសាងសង់ផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។

## ជំពូកទី៤

## ការត្រួតពិនិត្យនិងបញ្ជាក់ការងារជួសជុល

**ប្រការ១៩**._

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារជួសជុល មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យការងារជួសជុលឱ្យស្របតាមគម្រោងប្លង់សម្រាប់ការងារជួសជុលដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត
- ត្រួតពិនិត្យការងារជួសជុលឱ្យអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ស្តង់ដាកម្ពុជា និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ត្រួតពិនិត្យការដ្ឋានសំណង់ឱ្យដំណើរការដោយគោរពតាមលិខិតបទដ្ឋានគតិយុត្តនិងគោល-ការណ៍ណែនាំពាក់ព័ន្ធ មានជាអាទិ៍ សុវត្ថិភាព បរិស្ថាន អនាម័យ សន្តិសុខ សណ្ដាប់ធ្នាប់នៅការដ្ឋានសំណង់

- បញ្ជាក់ថាសំណង់ដែលបានជួសជុលមានគុណភាពនិងសុវត្ថិភាព ស្របតាមទំហំ ប្រភេទ និងមុខងារប្រើប្រាស់នៃសំណង់។

**ប្រការ២០._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារជួសជុល ត្រូវអនុវត្តលើការងារដូចខាងក្រោម៖

១- ការងារជួសជុលផ្នែកគ្រឿងផ្គុំសំណង់ មានជាអាទិ៍ គ្រឿងផ្គុំផ្នែកខាងក្រោម គ្រឿងផ្គុំផ្នែកខាងលើ និងពុម្ព។

២- ការងារជួសជុលផ្នែកប្រព័ន្ធទឹកកខ្វក់និងប្រព័ន្ធទឹកភ្លៀង មានជាអាទិ៍ បណ្តាញលូបង្ហូរទឹកកខ្វក់ បណ្តាញលូបង្ហូរទឹកភ្លៀង អាងសិបទិច អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ទទឹកភ្លៀង អាងស្តុកទឹកភ្លៀង អាងប្រព្រឹត្តិកម្មសម្អាតសំណល់រាវ។

៣- ការងារជួសជុលផ្នែកស្ថាបត្យកម្ម មានជាអាទិ៍ ដំបូល ទ្វារ បង្អួច ជណ្តើរ កម្ពស់ ច្រកចេញចូល លំហខ្យល់ចេញចូល ពន្លឺ ចំណតយានយន្តក្នុងអគារ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព មុខងារសមាសភាគសំណង់ ភ្លើងសញ្ញាអាកាសចរលើដំបូលអគារ ឧបករណ៍ការពាររន្ទះ។

៤- ការងារជួសជុលផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។

## ជំពូកទី៥
## ការត្រួតពិនិត្យនិងបញ្ជាក់ការងារកែប្រែ

**ប្រការ២១._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារកែប្រែ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យការងារកែប្រែឱ្យស្របតាមគម្រោងប្លង់សម្រាប់ការងារកែប្រែដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចនិងមន្ត្រីមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត
- ត្រួតពិនិត្យការងារកែប្រែឱ្យអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ស្តង់ដាកម្ពុជា និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ត្រួតពិនិត្យការដ្ឋានសំណង់ឱ្យដំណើរការដោយគោរពតាមលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំពាក់ព័ន្ធ មានជាអាទិ៍ សុវត្ថិភាព បរិស្ថាន អនាម័យ សន្តិសុខ សណ្តាប់ធ្នាប់នៅការដ្ឋានសំណង់
- បញ្ជាក់ថាសំណង់ដែលបានកែប្រែមានគុណភាពនិងសុវត្ថិភាព ស្របតាមទំហំ ប្រភេទ និងមុខងារប្រើប្រាស់នៃសំណង់។

**ប្រការ២២._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារជួសជុល ត្រូវអនុវត្តលើការងារដូចខាងក្រោម៖

១- ការងារកែប្រែផ្នែកនគរូបនីយកម្ម មានជាអាទិ៍ ប្លង់ទីតាំង ផ្លាតមាត់ កម្ពស់សំណង់ សន្ទស្សន៍ប្រើប្រាស់ដីផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ការប្រើប្រាស់លំហសាធារណៈនិងផ្ទៃបៃតង ចំណតយានយន្តក្រៅអគារ។

២- ការងារកែប្រែផ្នែកគ្រឿងផ្គុំសំណង់ មានជាអាទិ៍ គ្រឿងផ្គុំផ្នែកខាងក្រោម គ្រឿងផ្គុំផ្នែកខាងលើ និងពុម្ព។

៣- ការងារកែប្រែផ្នែកប្រព័ន្ធទឹកកខ្វក់និងប្រព័ន្ធទឹកភ្លៀង មានជាអាទិ៍ បណ្ដាញលូបង្ហូរទឹកកខ្វក់ បណ្ដាញលូបង្ហូរទឹកភ្លៀង អាងសិបទិច អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ទទឹកភ្លៀង អាងស្តុកទឹកភ្លៀង អាងប្រព្រឹត្តិកម្មសម្អាតសំណល់រាវ។

៤- ការងារកែប្រែផ្នែកស្ថាបត្យកម្ម មានជាអាទិ៍ ដំបូល ទ្វារ បង្អួច ជណ្ដើរ កម្ពស់ ច្រកចេញចូល លំហខ្យល់ចេញចូល ពន្លឺ ចំណតយានយន្តក្នុងអគារ ហេដ្ឋារចនាសម្ព័ន្ធរបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព មុខងារសមាសភាគសំណង់ ភ្លើងសញ្ញាអាកាសចរលើដំបូលអគារ ឧបករណ៍ការពាររន្ទះ។

៥- ការងារកែប្រែផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។

## ជំពូកទី៦

## ការងារត្រួតពិនិត្យនិងបញ្ជាក់ការងាររុះរើ

### ផ្នែកទី១

### ការងារត្រួតពិនិត្យនិងបញ្ជាក់ការងាររុះរើទាំងស្រុង

**ប្រការ២៣._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងាររុះរើទាំងស្រុង មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យការងាររុះរើឱ្យស្របតាមគម្រោងប្លង់សម្រាប់ការងាររុះរើដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចនិងមន្ត្រីមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត
- ត្រួតពិនិត្យការងាររុះរើឱ្យអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស និងបទប្បញ្ញត្តិជាធរមានដទៃទៀត

- ត្រួតពិនិត្យការដ្ឋានសំណង់ឱ្យដំណើរការដោយគោរពតាមលិខិតបទដ្ឋានគតិយុត្តនិង គោលការណ៍ណែនាំពាក់ព័ន្ធ មានជាអាទិ៍ សុវត្ថិភាព បរិស្ថាន អនាម័យ សន្តិសុខ សណ្តាប់ធ្នាប់ នៅការដ្ឋានសំណង់។

**ប្រការ២៤._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងាររុះរើទាំងស្រុង ត្រូវអនុវត្តលើការងារដូចខាងក្រោម៖

១- ការងាររុះរើផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។

២- ការងាររុះរើផ្នែកគ្រឿងផ្គុំសំណង់ មានដូចជា គ្រឿងផ្គុំផ្នែកខាងលើនិងគ្រឿងផ្គុំផ្នែកខាង ក្រោម។

## ផ្នែកទី២

## ការងារត្រួតពិនិត្យនិងបញ្ជាក់ការងាររុះរើដោយផ្នែក

**ប្រការ២៥._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងាររុះរើដោយផ្នែក មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យការងាររុះរើឱ្យស្របតាមគម្រោងប្លង់សម្រាប់ការងាររុះរើដែលទទួលបានការ យល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចនិងមន្ត្រីមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត
- ត្រួតពិនិត្យការងាររុះរើឱ្យអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស និងបទប្បញ្ញត្តិជាធរមាន ដទៃទៀត
- ត្រួតពិនិត្យការដ្ឋានសំណង់ឱ្យដំណើរការដោយគោរពតាមលិខិតបទដ្ឋានគតិយុត្តនិងគោល-ការណ៍ណែនាំពាក់ព័ន្ធ មានជាអាទិ៍ សុវត្ថិភាព បរិស្ថាន អនាម័យ សន្តិសុខ សណ្តាប់ធ្នាប់ នៅការដ្ឋានសំណង់
- បញ្ជាក់ថាសមាសភាគនៃសំណង់ដែលនៅសល់មានគុណភាពនិងសុវត្ថិភាពអាចប្រើប្រាស់ បានក្នុងមុខងារដដែលឬមុខងារថ្មី។

**ប្រការ២៦._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងាររុះរើដោយផ្នែក ត្រូវអនុវត្តលើការងារដូចខាងក្រោម៖

១- ការងាររុះរើផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។

២- ការងាររុះរើផ្នែកស្ថាបត្យកម្ម។

៣- ការងាររុះរើផ្នែកគ្រឿងផ្គុំសំណង់ មានដូចជា គ្រឿងផ្គុំផ្នែកខាងក្រោម គ្រឿងផ្គុំផ្នែកខាងលើ និងការងារពុម្ព។

## ជំពូកទី៧

## ការត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ

**ប្រការ២៧.**_

ក្នុងករណីគម្រោងអភិវឌ្ឍន៍បុរី ពុំចែកជាច្រើនដំណាក់កាលនៃការអនុវត្តគម្រោង លិខិតបញ្ជាក់អនុលោមភាពមួយ ត្រូវចេញសម្រាប់សំណង់នៃគម្រោងទាំងមូល ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- សំណង់ទាំងអស់នៃគម្រោងត្រូវបានសាងសង់រួចស្របតាមគម្រោងប្លង់ និងអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ការងារសាងសង់បរិក្ខារសាធារណៈជាមូលដ្ឋាននៅក្នុងគម្រោង ត្រូវបានបញ្ចប់រួចរាល់ ដូចមានកំណត់នៅក្នុងលិខិតអនុញ្ញាតអភិវឌ្ឍដី ស្របតាមគម្រោងប្លង់ និងអនុលោមតាមបទប្បញ្ញត្តិជាធរមាន មានជាអាទិ៍ ចំណត ប្រព័ន្ធអគ្គិសនី ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ ប្រព័ន្ធលូ ផ្លូវ លំហសាធារណៈនិងផ្ទៃបៃតង ប្រព័ន្ធបំភ្លឺសាធារណៈ។

**ប្រការ២៨.**_

ក្នុងករណីគម្រោងអភិវឌ្ឍន៍បុរី មានចែកជាច្រើនដំណាក់កាលនៃការអនុវត្តគម្រោង ដូចមានកំណត់នៅក្នុងលិខិតអនុញ្ញាតអភិវឌ្ឍដី លិខិតបញ្ជាក់អនុលោមភាពមួយ ត្រូវចេញសម្រាប់សំណង់ថ្មីទាំងអស់នៃដំណាក់កាលនៃការអនុវត្តគម្រោង ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- សំណង់ទាំងនោះ ត្រូវបានសាងសង់រួចស្របតាមគម្រោងប្លង់ និងអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ការងារសាងសង់បរិក្ខារសាធារណៈជាមូលដ្ឋានត្រូវបានសាងសង់រួចរាល់សម្រាប់ដំណាក់កាលនៃការអនុវត្តគម្រោងដែលជាកម្មវត្ថុនៃលិខិតបញ្ជាក់អនុលោមភាព ដូចមានកំណត់នៅក្នុងលិខិតអនុញ្ញាតអភិវឌ្ឍដី ស្របតាមគម្រោងប្លង់ និងអនុលោមតាមបទប្បញ្ញត្តិជាធរមាន មានជាអាទិ៍ ចំណត ប្រព័ន្ធអគ្គិសនី ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ ប្រព័ន្ធលូ ផ្លូវ លំហសាធារណៈនិងផ្ទៃបៃតង ប្រព័ន្ធបំភ្លឺសាធារណៈ
- ការងារសាងសង់បរិក្ខារសាធារណៈជាមូលដ្ឋាននៅក្នុងដំណាក់កាលផ្សេងទៀត ត្រូវបានអនុវត្តត្រឹមត្រូវតាមការកំណត់នៅក្នុងលិខិតអនុញ្ញាតអភិវឌ្ឍដី ស្របតាមគម្រោងប្លង់ និងអនុលោមតាមបទប្បញ្ញត្តិជាធរមាន មានជាអាទិ៍ ប្រព័ន្ធលូ ផ្លូវ លំហសាធារណៈនិងផ្ទៃបៃតង។

**ប្រការ២៩.**_

លិខិតបញ្ជាក់អនុលោមភាពនៃការងារសាងសង់សំណង់ថ្មីដែលជាផ្នែកនៃអគារសហកម្មសិទ្ធិ អាចចេញក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- គ្រឿងផ្ទុំទាំងមូលនៃសំណង់និងជញ្ជាំងខណ្ឌចំណែកឯកជន ត្រូវបានសាងសង់រួច ស្របតាមគម្រោងប្លង់និងអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវបានសាងសង់រួចស្របតាមគម្រោងប្លង់ និងអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ការងារសាងសង់បរិក្ខារសាធារណៈជាមូលដ្ឋាននៅក្នុងផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវបានបញ្ចប់រួចរាល់ស្របតាមគម្រោងប្លង់និងអនុលោមតាមបទប្បញ្ញត្តិជាធរមាន មានជាអាទិ៍ ចំណត ជណ្តើរ ជណ្តើរយន្ត ប្រព័ន្ធអគ្គិសនី ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ ប្រព័ន្ធលូ ផ្លូវ លំហសាធារណៈ និងផ្ទៃបៃតង ប្រព័ន្ធបំភ្លឺសាធារណៈ។

**ប្រការ៣០._**

ក្នុងករណីគម្រោងអភិវឌ្ឍអចលនវត្ថុមានសំណង់ច្រើន និងមានលិខិតអនុញ្ញាតសាងសង់តែមួយ លិខិតបញ្ជាក់អនុលោមភាពអាចចេញសម្រាប់សំណង់ថ្មីនីមួយៗនៅក្នុងគម្រោង ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- សំណង់ថ្មីនីមួយៗនៅក្នុងគម្រោងនោះ ត្រូវបានសាងសង់រួចស្របតាមគម្រោងប្លង់ និងអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ការងារសាងសង់បរិក្ខារសាធារណៈជាមូលដ្ឋានត្រូវបានសាងសង់រួចរាល់សម្រាប់ដំណាក់កាលនៃគម្រោងអភិវឌ្ឍអចលនវត្ថុនោះ ដូចមានកំណត់នៅក្នុងលិខិតអនុញ្ញាតអភិវឌ្ឍដីមានជាអាទិ៍ ចំណត ប្រព័ន្ធអគ្គិសនី ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ ប្រព័ន្ធលូ ផ្លូវ លំហសាធារណៈនិងផ្ទៃបៃតង ប្រព័ន្ធបំភ្លឺសាធារណៈ ស្របតាមគម្រោងប្លង់និងអនុលោមតាមបទប្បញ្ញត្តិជាធរមាន
- ការងារសាងសង់បរិក្ខារសាធារណៈជាមូលដ្ឋាននៅក្នុងដំណាក់កាលផ្សេងទៀត ត្រូវបានអនុវត្តត្រឹមត្រូវតាមការកំណត់នៅក្នុងលិខិតអនុញ្ញាតអភិវឌ្ឍដី ស្របតាមគម្រោងប្លង់ និងអនុលោមតាមបទប្បញ្ញត្តិជាធរមាន មានជាអាទិ៍ ប្រព័ន្ធលូ ផ្លូវ លំហសាធារណៈនិងផ្ទៃបៃតង។

## ជំពូកទី៨
## កិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់

**ប្រការ៣១._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវចុះកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ជាមួយម្ចាស់សំណង់ទៅតាមប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណ។

កិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវមានចែងខអប្បបរមាដូចតទៅ៖

- កាលបរិច្ឆេទបង្កើតកិច្ចសន្យា
- អត្តសញ្ញាណរបស់ភាគីនៃកិច្ចសន្យា
- ទីតាំង ទំហំ និងប្រភេទការងារ
- តម្លៃនៃកិច្ចសន្យា កាលបរិច្ឆេទ និងរបៀបនៃការទូទាត់
- ការអះអាងអំពីការអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់
- ការអះអាងអំពីអនុលោមភាពនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ការផ្តល់ឯកសារបច្ចេកទេសសម្រាប់ការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើតាមទំហំនិងប្រភេទនៃការងារ
- ការធានាការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា
- លក្ខខណ្ឌនៃការកែប្រែនិងរំលាយកិច្ចសន្យា
- ការធានារ៉ាប់រងវិជ្ជាជីវៈនិងការទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កឡើងដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើ
- លក្ខខណ្ឌពាក់ព័ន្ធនឹងករណីប្រធានសក្តិ
- ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចសន្យា។

គំរូទម្រង់នៃកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ជាឧបសម្ព័ន្ធ១០នៃប្រកាសនេះ។

**ប្រការ៣២._**

កម្រៃសេវានិងកាលបរិច្ឆេទនៃការទូទាត់សម្រាប់កិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវធ្វើតាមការព្រមព្រៀងរវាងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់និងម្ចាស់សំណង់។

ក្នុងករណីគ្មានការព្រមព្រៀងរវាងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់និងម្ចាស់សំណង់ កម្រៃសេវា និងកាលបរិច្ឆេទនៃការទូទាត់សម្រាប់កិច្ចសន្យាត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើ ត្រូវអនុវត្ត ដូចខាងក្រោម៖

- ទូទាត់យ៉ាងតិច១០(ដប់)ភាគរយនៃតម្លៃកិច្ចសន្យានៅពេលចុះកិច្ចសន្យា
- ទូទាត់ជាដំណាក់កាលក្នុងរយៈពេលមិនតិចជាង៣០(សាមសិប)ថ្ងៃនិងមិនលើសពី៩០(កៅសិប) ថ្ងៃម្តង
- ទូទាត់បង្គ្រប់១០(ដប់)ភាគរយនៃតម្លៃកិច្ចសន្យានៅពេលប្រគល់ទទួលរបាយការណ៍ស្តីពីការ ត្រួតពិនិត្យនិងបញ្ជាក់សំណង់និងលិខិតបញ្ជាក់អនុលោមភាព។

ក្នុងករណីគ្មានការព្រមព្រៀងជាមុនរវាងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់និងម្ចាស់សំណង់ ម្ចាស់សំណង់ត្រូវទូទាត់កម្រៃសេវាបន្ថែមស្មើនឹងតម្លៃដែលត្រូវទូទាត់ជាដំណាក់កាលក្នុងកិច្ចសន្យា ជូន អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ក្នុងករណីការងារសាងសង់ឬរុះរើអនុវត្តយឺតយ៉ាវលើសពីរយៈពេល ដែលបានកំណត់នៅក្នុងកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ។

## ជំពូកទី៩

## បទប្បញ្ញត្តិបច្ចេកទេសសំណង់

### ប្រការ៣៣._

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជា ធរមានដទៃទៀតនៅក្នុងការអនុវត្តការងាររបស់ខ្លួន។

### ប្រការ៣៤._

ក្នុងករណីពុំមានបទប្បញ្ញត្តិបច្ចេកទេសសំណង់សម្រាប់ការងារសំណង់ណាមួយ អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ត្រូវអនុវត្តបទដ្ឋានបច្ចេកទេសសំណង់ណាមួយ ដែលមានការទទួលស្គាល់កម្រិត អន្តរជាតិឬកម្រិតតំបន់ តាមការជ្រើសរើសរបស់អ្នកសិក្សាគម្រោងប្លង់ អ្នកសាងសង់ ឬមន្ទីរពិសោធន៍ សំណង់ និងត្រូវត្រួតពិនិត្យនិងបញ្ជាក់លើផ្នែកដែលពាក់ព័ន្ធនឹងផ្នែកសុវត្ថិភាពសំណង់តែប៉ុណ្ណោះ។ ក្នុង ករណីនេះ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវអះអាងអំពីចំណេះដឹងរបស់ខ្លួនក្នុងការអនុវត្តបទដ្ឋាន នោះនៅក្នុងរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវស្របតាមលក្ខខណ្ឌ សេដ្ឋកិច្ច សង្គម ភូមិសាស្ត្រ អាកាសធាតុ បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី១០

## ការប្ដឹងតវ៉ា

**ប្រការ៣៥._**

ម្ចាស់សំណង់ ឬអ្នកសាងសង់ដែលរងការខូចខាតឬមានការបារម្ភជាក់ស្ដែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិឬកាតព្វកិច្ចរបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ជាតិដើម្បីធ្វើការសម្រុះសម្រួល មុននឹងប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

## ជំពូកទី១១

## អវសានប្បញ្ញត្តិ

**ប្រការ៣៦._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣៧._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

**“ដើម្បីជូនជ្រាប”**

- សាលារាជធានី ខេត្ត
- ដូចប្រការ៣៧ **“ដើម្បីអនុវត្ត”**
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃប្រកាសលេខ ...១២៣ ដនសក.ប្រក... ចុះថ្ងៃទី ...៣០... ខែ ធ្នូ... ឆ្នាំ២០២១ ស្ដីពីបែបបទ
នៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់និងរុះរើផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| ឈ្មោះនិង/ឬរូបសញ្ញា<br>អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ |
|---|

ថ្ងៃ ..................... ខែ .......... ឆ្នាំ ....... ......ស័ក ព.ស.២៥..

.......................... ថ្ងៃទី .......... ខែ ............... ឆ្នាំ២០ .......

## លិខិតប្រគល់-ទទួលឯកសារបច្ចេកទេស

យោងពាក្យស្នើសុំ/កិច្ចសន្យាផ្ដល់សេវាកម្មត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់និងរុះរើ ......
..........................................................................................................................
ចុះថ្ងៃទី ............ ខែ ........... ឆ្នាំ ..............

- □ គម្រោងប្លង់ស្ថាបត្យកម្ម
- □ គម្រោងប្លង់គ្រឿងផ្គុំសំណង់
- □ គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក
- □ សេចក្ដីណែនាំបច្ចេកទេស
- □ ប្លង់សម្រង់សំណង់
- □ ប្លង់សម្រង់តាមការសាងសង់ជាក់ស្ដែង
- □ វិញ្ញាបនបត្រប្រើប្រាស់សំណង់
- □ ឯកសារសិក្សាភូគព្ភសាស្ត្រ
- □ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- □ ឯកសារសិក្សាសមិទ្ធិលទ្ធកម្ម
- □ សៀវភៅបន្ទុកនៃការងារសាងសង់
- □ របាយការណ៍ស្ដីពីការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- □ លិខិតបញ្ជាក់អនុលោមភាព
- □ របាយការណ៍ស្ដីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់
- □ របាយការណ៍ស្ដីពីការពិសោធន៍
- □ របាយការណ៍ស្ដីពីការគណនា
- □ របាយការណ៍ស្ដីពីការធ្វើកោសល្យវិច័យសំណង់
- □ គម្រោងប្លង់ឬរបាយការណ៍បច្ចេកទេសដទៃទៀត។
- □ ឯកសារពាក់ព័ន្ធផ្សេងៗ៖

| **ហត្ថលេខាអ្នកប្រគល់** | **ហត្ថលេខាអ្នកទទួល** |
|---|---|
| ឈ្មោះ ៖ ........................ | ឈ្មោះ ៖ ........................ |
| លេខទូរសព្ទ ៖ ........................ | លេខទូរសព្ទ ៖ ........................ |

ឧបសម្ព័ន្ធ២នៃប្រកាសលេខ ១២៦ ដនសប/ប្រ.កក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២១ ស្ដីពីបែបបទ
នៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់និងរុះរើផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| ឈ្មោះនិង/ឬរូបសញ្ញា<br>អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ |
|---|

**សូមជម្រាបជូន**

**លោក................................ លោកស្រី/.................................**

**កម្មវត្ថុ** ៖ សំណើសុំកែតម្រូវ ...............................................................................................

**យោង** ៖ -ប្រកាសលេខ ............................... ចុះថ្ងៃទី ........... ខែ ............ ឆ្នាំ២០២១ ស្ដីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់និងរុះរើផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់

-គម្រោងប្លង់ ............................................................................ ..............................

-ពាក្យស្នើសុំឬកិច្ចសន្យាត្រួតពិនិត្យនិងបញ្ជាក់ ....................................................... ចុះថ្ងៃទី ............ខែ .............ឆ្នាំ ..................

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក/លោកស្រីជ្រាបថាការងារ ...................................................................................................... មានភាពមិនស្របតាមគម្រោងប្លង់និង/ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតដូចខាងក្រោម៖

១. ................................................................................ មិនស្របឬមិនអនុលោមតាម ..........................................................................................................

២. ................................................................................ មិនស្របឬមិនអនុលោមតាម ..........................................................................................................

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រីចាត់ចែងកែតម្រូវឱ្យស្របតាមគម្រោងប្លង់និង/ឬអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត។

សូមលោក/លោកស្រី ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ថ្ងៃ .................... ខែ .......... ឆ្នាំ ....... ......ស័ក ព.ស.២៥..

ធ្វើនៅ ....................... ថ្ងៃទី ......... ខែ ......... ឆ្នាំ២០ ...........

ហត្ថលេខា គោត្តនាមនិងនាម និងត្រាវិជ្ជាជីវៈរបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ឬ

ហត្ថលេខា គោត្តនាមនិងនាមនាយកបច្ចេកទេស និងត្រារបស់ក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ឬ

ហត្ថលេខា គោត្តនាមនិងនាមប្រធានក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់ និងត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឧបសម្ព័ន្ធ៣នៃប្រកាសលេខ១២៦.ដនសណ/ប្រ.ក.និ.ភ ចុះថ្ងៃទី ..៣០... ខែ ..ធ្នូ... ឆ្នាំ២០២១ ស្តីពីបែបបទ
នៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់និងរុះរើផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| |
|---|
| ឈ្មោះនិង/ឬរូបសញ្ញា<br>អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់<br>លេខអាជ្ញាបណ្ណ |

**របាយការណ៍**

**ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់**

**ដំណាក់កាល**.................................................................................

**១- ព័ត៌មានទូទៅ**

**ក. ម្ចាស់សំណង់** .................................................... តំណាងដោយ .................................

កាន់អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនលេខ ..................................................ទីលំនៅបច្ចុប្បន្ន

ផ្ទះ/អគារលេខ .................ផ្លូវ .................... ភូមិ ................. ឃុំ/សង្កាត់ ....................

ក្រុង/ស្រុក/ខណ្ឌ ..............................រាជធានី/ខេត្ត ...........................។

**ខ. អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់** ................................................................... តំណាង

ដោយ ........................................................ មានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

ផ្នែក ............................ កម្រិត .........លេខ ............................ .. ចុះថ្ងៃទី .........

ខែ ............ ឆ្នាំ .......... មានទីលំនៅបច្ចុប្បន្នផ្ទះ/អគារលេខ ............................ ជាន់ទី .........

ផ្លូវ ...........ភូមិ .................ឃុំ/សង្កាត់ ........................ ក្រុង/ស្រុក/ខណ្ឌ .......................

**គ. អ្នកសាងសង់**.........................................................................................................

តំណាងដោយ ................................................................................................ មានអាជ្ញាបណ្ណ

.............. ............................. កម្រិត .............. លេខ ......... ចុះថ្ងៃទី ......... ខែ ............

ឆ្នាំ .......... មានទីលំនៅបច្ចុប្បន្នផ្ទះ/អគារលេខ .....................ជាន់ទី .........ផ្លូវ ...........

ភូមិ .................ឃុំ/សង្កាត់ ........................ ក្រុង/ស្រុក/ខណ្ឌ ....................................

**ឃ. គម្រោងប្លង់**

- គម្រោងសាងសង់ ......................................................................................................

.............................................................................................................................

មានទីតាំងស្ថិតនៅដីឡូត៍ .................. ផ្លូវ ............ ភូមិ ................ ឃុំ/ សង្កាត់ ...................
ក្រុង/ ស្រុក/ ខណ្ឌ ...................... រាជធានី/ ខេត្ត ..........................

- សិក្សាដោយ ...........................................................................................................
- មុខងារប្រើប្រាស់សំណង់ ...........................................................................................
- ប្រភេទការងារ .........................................................................................................
- លិខិតអនុញ្ញាតសាងសង់លេខ ............................. ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ ..........
- លិខិតអនុញ្ញាតបើកការដ្ឋានសំណង់លេខ ................. ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ ..........

## ២- ការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់សំណង់ថ្មីផ្នែកគ្រឿងផ្គុំសំណង់

### ក. ការងារសាងសង់គ្រឿងផ្គុំផ្នែកខាងក្រោម៖

- ការងារគ្រឹះ .......................................................................................................
.......................................................................................................
.......................................................................................................
.......................................................................................................
- ការងារគម្របសសរគ្រឹះ .......................................................................................
.......................................................................................................
.......................................................................................................
.......................................................................................................
- ការងារជញ្ជាំងទប់ដី ...........................................................................................
.......................................................................................................
.......................................................................................................
.......................................................................................................
- ការងារទប់ជញ្ជាំង .............................................................................................
.......................................................................................................
.......................................................................................................
.......................................................................................................
- ការងារធ្នឹមក្រវ៉ាត់ ............................................................................................
.......................................................................................................

..............................................................................................................

..............................................................................................................

- ការងារសសរតឿ ..........................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

- ..............................................................................................................

..............................................................................................................

..............................................................................................................

**ខ. គ្រឿងផ្គុំផ្នែកខាងលើ៖**

- ការងារធ្នឹម ...............................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

- ការងារសសរ ..............................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

- ការងារកម្រាលខណ្ឌ ....................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

- ការងារជញ្ជាំងទ្របន្ទុក ..............................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

- ការងារជណ្ដើរ ...........................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

- ការងារដំបូល ..........................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

- ..........................................................................................................

..........................................................................................................

..........................................................................................................

**គ. ការងារពុម្ព៖**

- ការងាររៀបពុម្ព ......................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

- ការងាររន្ទា ...........................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

- ការងារជន្ទល ..........................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

- ការងារដែកពង្រឹង......................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

- ..............................................................................................................................

..............................................................................................................................

..............................................................................................................................

ឃ. ការងារសាងសង់ផ្នែកសម្ភារៈសំណង់និងផលិតផលសំណង់៖

- ..............................................................................................................................

..............................................................................................................................

..............................................................................................................................

- ..............................................................................................................................

..............................................................................................................................

..............................................................................................................................

៣- ការងារត្រួតពិនិត្យនិងបញ្ជាក់ការងារជួសជុលផ្នែកគ្រឿងផ្គុំសំណង់

ក. ការងារគ្រឿងផ្គុំផ្នែកខាងក្រោម៖

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

ខ. ការងារគ្រឿងផ្គុំផ្នែកខាងលើ៖

..............................................................................................................................

..............................................................................................................................

..............................................................................................................................

